ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សាលាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៥៦៨
ចុះថ្ងៃទី ០៤-០៧-២០១១
សាលដីកា
លេខ ៖ ៥៤ "ក្រ.III.ស"
ចុះថ្ងៃទី ០៦-០៨-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

## ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted]

## ក្រឡាបញ្ជី

កញ្ញា [redacted]

Sept/2009 — June/2011 Judgment — June/2010 — Dec/2013 (App — 4 ឆ្នាំ

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៥៦៨ ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១១ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] កែវ ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើត និងរស់នៅ [redacted] ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted]) ប្រពន្ធឈ្មោះ [redacted] មានកូន ៥នាក់ ទោសគ្មានពីមុន ឃុំខ្លួនតាមដីកាលេខ ១០៦ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០០៩។

មានលោក [redacted] វិបុល ជាមេធាវីការពារ។

ជាប់ចោទពីបទ: ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅភូមិកណ្តាល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី នៃច្បាប់វិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ដំណើររឿងមានដូចតទៅ

កាលពីប៉ុន្មានឆ្នាំមុនឈ្មោះ ផឹង កែវ បានរត់ទូកដរពីស្ទឹងត្រែងទៅវីនខាំ ហើយបានស្គាល់ឈ្មោះ [redacted] វ៉ាន់ ជនជាតិឡាវ ហើយឈ្មោះនេះបានប្រាប់ឱ្យជួយរកម៉ូយដើម្បីជួយទិញគ្រឿងញៀន បន្ទាប់ពីរកម៉ូយបានហើយឈ្មោះ [redacted]កែវ បានទំនាក់ទំនងរកអ្នកទិញដោយទាក់ទងគ្នាតាមទូរស័ព្ទ។ លុះដល់ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៣រសៀល ឈ្មោះ [redacted] វ៉ាន់ បានទូរស័ព្ទទៅហៅឈ្មោះ [redacted] កែវ ឱ្យទៅទទួលយកថ្នាំញៀនត្រង់ចំណុចដើមអំពិល ពេលទទួលបានថ្នាំញៀនហើយ ឈ្មោះ [redacted] កែវ បាន[illegible]ខេត្តស្ទឹង

ត្រែង រួចទៅដេកនៅតាមវាលខ្សាច់កោះស្នែង។ នៅព្រឹកថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៧ និង៤០នាទី ត្រូវសមត្ថកិច្ចបង្ក្រាបឃាត់ខ្លួននាំមកស្នងការនគរបាលខេត្តស្ទឹងត្រែង ដើម្បីចាត់ការតាមនីតិវិធីតែម្តង។

បានឃើញ សាលក្រមបៀបលេខ ១៥ ខ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តស្ទឹងត្រែង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ចាត់របៀបបង្វិលសំណុំរឿងលេខ ១០២ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០០៩ ទៅចៅក្រមស៊ើបសួរ ដើម្បីស៊ើបសួរបន្ថែមលើ:

ក- ឈ្មោះ [redacted] វ៉ាន់ ជនជាតិឡាវ រស់នៅប៉ាកសេ តាមដែលអាចធ្វើទៅបាន បើមានតម្រុយត្រូវធ្វើកំណត់ហេតុ។

ខ- ឱ្យស្រាវជ្រាវរកឈ្មោះ [redacted] រីតា អាយុប្រហែល ៥០ឆ្នាំ ដែលមានភិនភាគមាឌស្តើងខ្ពស់ សម្បុរស សក់ស្កូត សិតសក់វែកចំហៀង ដាក់ធ្មេញមាស តើមានដែរ ឬទេ ប្រសិនបើមានពិតមែន សុំផ្តល់រូបថតមកសាលាដំបូងខេត្តស្ទឹងត្រែងភ្ជាប់ជាមួយនឹងរបាយការណ៍របស់អង្គភាព តែបើពុំមានឈ្មោះនេះ សុំឱ្យមានជារបាយការណ៍ ប្រសិនបើឈ្មោះ[redacted] រីតា ជាអ្នកអនុវត្តន៍នូវវិធានបញ្ជាញ់ សុំឱ្យអង្គភាពរាយការណ៍។

គ- សុំឱ្យចៅក្រមស៊ើបសួរនៅផ្ទះសំណាក់ លីលី ខេត្តស្ទឹងត្រែង សាកសួរថា តើមានវត្តមានឈ្មោះ [redacted] រីតា ដែលមានភិនភាគដូចរៀបរាប់ក្នុងចំណុច (ខ) នៃសាលក្រមបៀបលេខ ១៥ ខ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១០ ទៅជួបបន្ទប់លេខ ១០៥ កាលពីថ្ងៃទី ២០, ២១, ២២ ខែកញ្ញា ឆ្នាំ២០០៩ ដែរឬទេ។

២- បង្គាប់ឱ្យពន្ធនាគារខេត្តស្ទឹងត្រែងបន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] កែវ ជាបណ្តោះអាសន្នរហូត ដល់មានការសម្រេចជាថ្មី។

៣- ក្រោយពេលបញ្ចប់ការស៊ើបសួរ សុំបង្វិលសំណុំរឿងលេខ ១០២ អក ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០០៩ ព្រមទាំងការសម្រេចជាថ្មី។

៤- សំណុំរឿងនេះនឹងលើកទៅជំនុំជម្រះនៅពេលក្រោយ។

៥- សាលក្រមនេះជំនុំជម្រះជាសាធារណៈ ប្រកាសចំពោះមុខជនជាប់ចោទឈ្មោះ[redacted]កែវ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០ ខ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តស្ទឹងត្រែង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted] កែវ ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ (ម្ភៃឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៩ និងពិន័យជាប្រាក់ ៤០.០០០.០០០រៀល (សែសិបលានរៀល) ដើម្បីបង់ចូលថវិការដ្ឋ ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិកណ្តាល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៩ តាមមាត្រា ៣៣ ថ្មី កថាខណ្ឌ ៤ ចំណុច គ នៃច្បាប់វិស្តីពីសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- វត្ថុតាងគ្រឿងញៀនប្រភេទហេរ៉ូអ៊ីន ដុំម្សៅពណ៌ក្រម៉ៅចំនួន ៣៣២,២ក្រាម ត្រូវរឹបអូស និងបំផ្លាញចោល។

៣- សាលក្រមនេះជំនុំជម្រះជាសាធារណៈ និងចំពោះមុខជនជាប់ចោទនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១១ និងប្រកាសចំពោះមុខជនជាប់ចោទឈ្មោះ[redacted]កែវ នៅថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ៩ និង៤៥នាទី ព្រឹក។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] កែវ ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០ ខ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ របស់ សាលាដំបូងខេត្តស្ទឹងត្រែង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] កែវ បានឆ្លើយនៅសាលាដំបូងខេត្តស្ទឹងត្រែង។

### សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] កែវ បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ យោងតាមមាត្រា ៣៧៥ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] កែវ ដូចបទចោទប្រកាន់របស់អយ្យការសាលាដំបូង ហើយរឿងនេះជាបទល្មើសជាក់ស្តែង សមត្ថកិច្ចឃាត់ខ្លួនជនល្មើសបានទាំងវត្ថុតាងគ្រឿងញៀន ជនជាប់ចោទទទួលសារភាព។

ដូច្នេះ សាលក្រមព្រហ្មទណ្ឌលេខ ១០ ខ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តស្ទឹងត្រែង ដែលបានសម្រេចមកនេះត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការ។

### សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ [redacted] វិបុល

រឿងនេះកូនក្តីខ្លួនពិតជាអ្នកកាន់កាប់គ្រឿងញៀនពិតប្រាកដមែន យោងតាមកំណត់ហេតុកោសលវិច័យ តែមានធាតុសុទ្ធ ១០៥,៣៣g ហើយការដែលកូនក្តីខ្លួនប្តឹងឧទ្ធរណ៍ គឺមានឈ្មោះ ផល និងឈ្មោះ គា ឲ្យគាត់ធ្វើជាផ្ទាក់ទាក់មេគ្រឿងញៀនឈ្មោះ [redacted] ឡាវ៉ាន់ ដោយឈ្មោះ គា ជាអ្នកធ្វើការនៅខាងគ្រឿងញៀន បានឲ្យកូនក្តីខ្លួនធ្វើជាផ្ទាក់ធ្វើយ៉ាងណាដើម្បីចាប់ឈ្មោះ [redacted] ឡាវ៉ាន់ នេះឲ្យបាន ហើយឈ្មោះ ផល បានសន្យាថា បើជោគជ័យនឹងឲ្យកូនក្តីខ្លួនធ្វើជាប៉ូលីស ក្នុងការទំនាក់ទំនងនេះឈ្មោះ ផល បានទិញទូរស័ព្ទឲ្យកូនក្តីខ្លួនដោយគាត់ជាអ្នកទិញឲ្យ ហើយរឿងនេះនៅសាលាដំបូងមេធាវីបានសុំធ្វើចាត់របៀបរកឈ្មោះ គា និងឈ្មោះ ផល តែមិនមានទេ។ ចំពោះសាក្សីសំខាន់មានតែឈ្មោះ ផល និងឈ្មោះ គា តែសាលាដំបូងចាត់របៀបដែរ តែមិនបានស៊ើបអង្កេតទេ ពេលនេះខ្លួនសំណូមពរ សុំក្រុមប្រឹក្សាសម្រេចចាត់របៀបដើម្បីស៊ើបរកឈ្មោះ គា និងឈ្មោះ ផល ដើម្បីស៊ើបរកសាវតា និងមុខរបររបស់ពួកគេ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា ផែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ ងឹម កែវ ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- តាមចម្លើយជនជាប់ចោទថា ខ្លួនបានស្គាល់ឈ្មោះ [redacted] វ៉ាន់ ជាជនជាតិឡាវ ជាយូរឆ្នាំមកហើយ។ ឈ្មោះ [redacted] វ៉ាន់ នេះបានឲ្យខ្លួនជួយរកម៉ូយទិញថ្នាំញៀន, ឯថ្នាំដែលសមត្ថកិច្ចចាប់ដកហូតបានពីខ្លួននេះ គឺខ្លួនបានទទួលពីឈ្មោះ [redacted] វ៉ាន់ ឲ្យខ្លួនយកទៅប្រគល់ឲ្យឈ្មោះ គា។ ថ្នាំញៀននេះមិនមែនជារបស់ខ្លួនទេ គឺជារបស់ឈ្មោះ [redacted] វ៉ាន់, ខ្លួនមិនបានទិញថ្នាំញៀននេះទេ។ ខ្លួនទើបតែបានទទួលថ្នាំញៀនពីឈ្មោះ [redacted] វ៉ាន់ តែមួយលើកនេះទេ។

៣- មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិកណ្តាល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៩ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី កថាខណ្ឌ ៤ ចំណុច គ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤- សំអាងហេតុ និងសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ១០ ខ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តស្ទឹងត្រែង មានភាពច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

## **ហេតុដូច្នេះ**
## **វិនិច្ឆ័យសេចក្តី**

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] កែវ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០ ខ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តស្ទឹងត្រែង ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៣ កំបាំងមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ៣១ ខែ ១២ ឆ្នាំ២ ០១៣
ក្រឡាបញ្ជី
[redacted]